ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
柬埔寨郵政銀行 CAMBODIA POST BANK PLC.

# ព្រឹត្តិបត្រព័ត៌មាន

ខែមករា ឆ្នាំ២០២៤
លេខ០៣



THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

**Cambodia Economic Update**
November 2023

## របាយការណ៍របស់ធនាគារពិភពលោក ស្ដីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

*ចេញផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា*

យោងតាមរបាយការណ៍របស់ធនាគារពិភពលោក ស្ដីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ចេញផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានគេព្យាករណ៍ថានឹងឈានដល់ ៥,៤% នៅឆ្នាំ ២០២៣ ដោយធ្លាក់ចុះតិចតួចពីការព្យាករណ៍ក្នុងខែឧសភាគឺ ៥,៥% និងអាចកើនឡើងដល់ ៥,៨% នៅឆ្នាំ២០២៤ និង ៦,១% នៅឆ្នាំ២០២៥ ដោយសារមានការកើនឡើងនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់។

ក្នុងរយៈពេលខ្លី ផលអវិជ្ជមាននៃការរាតត្បាតនៃជំងឺកូវីដ១៩ សង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន និងការរឹតបន្តឹងយ៉ាងខ្លាំងនៃគោលនយោបាយរូបិយវត្ថុក្នុងប្រទេសសេដ្ឋកិច្ចធំៗដើម្បីទប់ស្កាត់អតិផរណាខ្ពស់ត្រូវបានគេរំពឹងថានឹងបន្តប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជា។

...Supported by recovery of services...
*International arrivals (million)*




Economic growth was slower than anticipated...
*Real growth (percent)*



ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង កំណើនសេដ្ឋកិច្ច ត្រូវបានគេរំពឹងថានឹងវិលទៅមានសក្ដានុពលឡើងវិញ ដោយកើនដល់ពី ៦% ទៅ ៧% ដោយសារមានកំណើននៃការនាំចេញខ្លាំង និងកំណើនលំហូរវិនិយោគពីបរទេស ដោយសារកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី ការកើនឡើងយ៉ាងខ្លាំងនៃការវិនិយោគនៃវិស័យឯកជន និងសាធារណៈនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ និងកំណែទម្រង់រចនាសម្ព័ន្ធ។

សកម្មភាពសេដ្ឋកិច្ចនៅឆ្នាំនេះមានភាពយឺតយ៉ាវជាងការរំពឹងទុក ដោយសារការជាប់គាំងរចនាសម្ព័ន្ធថ្មីៗ និងឥទ្ធិពលខាងក្រៅ។ ភាពយឺតយ៉ាវនេះមានស្ទើរគ្រប់វិស័យ។ ទោះបីជាមានការស្ទុះងើបឡើងវិញយ៉ាងខ្លាំងនៃការមកដល់នៃភ្ញៀវអន្តរជាតិក៏ដោយ ក៏វិស័យទេសចរណ៍ និងធុរកិច្ចពីអន្តរជាតិនៅមានកម្រិតនៅឡើយ។ វិស័យសំណង់ និងអចលនវត្ថុនៅតែបន្តធ្លាក់ចុះផងដែរ ដែលបានបង្ហាញតាមរយៈការថយចុះនៃការនាំចូលសម្ភារៈសំណង់ ខណៈទីផ្សារលំនៅឋាននៅតែមិនទាន់មានស្ថិរភាព ដោយសារការកើនឡើងជាបន្តបន្ទាប់នៃការផ្គត់ផ្គង់ និងម៉ាក្រូសេដ្ឋកិច្ច ។

ការនាំចេញទំនិញរបស់កម្ពុជាមានការធ្លាក់ចុះ។ ក្នុងអំឡុងពេលប្រាំបីខែដំបូងនៃឆ្នាំ ២០២៣ ការនាំចេញទំនិញបានធ្លាក់ចុះ ២%។ ការនាំចូលទំនិញក៏បានធ្លាក់ចុះផងដែរ។ ការនាំចូលមាសបានធ្លាក់ចុះ ដែលធ្វើឱ្យឱនភាពគណនីចរន្តរួមតូច បើទោះបីជាការនាំចេញធ្លាក់ចុះក៏ដោយ។ នេះបានជួយបន្ធូរបន្ថយសម្ពាធលើអត្រាប្តូរប្រាក់ ដោយរក្សានៅតម្លៃ ៤.១០០ ខ្មែររៀលក្នុងមួយដុល្លារអាមេរិក។ ខណៈតម្លៃអាហារ និងប្រេងកើនឡើង អតិផរណាបានកើនឡើងតិចតួច ដោយឈានដល់ ៣,២% ក្នុងខែសីហា ឆ្នាំ២០២៣ កើនឡើងពី ២,៨% នៅចុងឆ្នាំ២០២២។ ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងដល់ ១៨,៥ ពាន់លានដុល្លារក្នុងខែសីហា ឆ្នាំ២០២៣ កើនឡើងពី ១៧,៧ ពាន់លានដុល្លារអាមេរិកនៅចុងឆ្នាំ២០២២ ដែលមានតម្លៃប្រហែលប្រាំពីរខែនៃការនាំចូល។

កំណើនឥណទានបានធ្លាក់ចុះមកត្រឹម ៧,៧% ក្នុងខែសីហា ឆ្នាំ២០២៣ ដែលជាកម្រិតទាបបំផុតក្នុងរយៈពេល ២០ឆ្នាំ ដោយថយចុះពី ២២,៧% ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២២ ហើយនេះបានបង្កជាការរឹតបន្តឹងការប្រើប្រាស់ក្នុងស្រុក។ ដោយសារសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្ពស់លើប្រាក់ដុល្លារ ប្រទេសកម្ពុជាបានប្រើប្រាស់គោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។ លក្ខខណ្ឌហិរញ្ញវត្ថុសកលបានរឹតត្បិត ដែលបណ្តាលមកពីការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកលដ៏លឿនបំផុតចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០មក។ យោងតាមរបាយការណ៍ពាក់កណ្តាលឆ្នាំ២០២៣ របស់ធនាគារជាតិនៃកម្ពុជា អនុបាតឥណទានមិនដំណើរការក្នុងវិស័យធនាគារគឺ៤.០% កើនឡើងពី ៣,២% នៅចុងឆ្នាំ២០២២ ខណៈអនុបាតឥណទានមិនដំណើរការក្នុងវិស័យមីក្រូហិរញ្ញវត្ថុគឺ៣,១% កើនឡើងពី ២,៦% នៅចុងឆ្នាំ២០២២។

Manufacturing sector’s jobs and factories




Garment, travel goods, and footwear jobs






បន្ទាប់ពីការងើបឡើងវិញយ៉ាងខ្លាំងនៅឆ្នាំ២០២២ ការប្រមូលចំណូលរបស់រដ្ឋាភិបាលបានធ្លាក់ចុះនៅឆ្នាំនេះ។ ដោយសារសកម្មភាពសេដ្ឋកិច្ចនៅយឺតនៅឡើយ ចំណូលរបស់ប្រទេសក៏មានការថមថយ។ ដូចគ្នាដែរ ពន្ធលើទំនិញ និងសេវាកម្ម ជាពិសេសពន្ធគយ និងអាករលើការនាំចូល ក៏បានធ្លាក់ចុះ ដោយសារការនាំចូលទំនិញ និងការប្រើប្រាស់ក្នុងស្រុកបានធ្លាក់ចុះ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិក៏បានបន្ធូរបន្ថយផងដែរ។ ប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) បានធ្លាក់ចុះតិចតួចមកនៅត្រឹម ២១,៣ ពាន់ពាន់លានរៀល (៥,១ពាន់លានដុល្លារ) ឬ ១៦% នៃផលិតផលក្នុងស្រុកសរុបក្នុងខែសីហា ឆ្នាំ២០២៣ ធ្លាក់ចុះពី ២១,៩ ពាន់លានរៀល (៥,៣ពាន់លានដុល្លារ) ឬ ១៧,៨% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២២។

ទីផ្សារការងារត្រូវបានរងផលប៉ះពាល់ដោយសារការធ្លាក់ចុះនៃការនាំចេញ។ ជាលទ្ធផលការងារនៅក្នុងវិស័យផលិតកម្ម (ផ្លូវការ) ដែលជាចំណែកដ៏ធំនៃការងារដែលមានប្រាក់ឈ្នួល ស្មើនឹង១៨% នៃប្រាក់បៀវត្សរ៍ បានធ្លាក់ចុះពី ១,០៥លានដុល្លារអាមេរិកក្នុងខែកក្កដា ឆ្នាំ២០២២ មកត្រឹម ១ លានដុល្លារអាមេរិកក្នុងខែឧសភា ឆ្នាំ២០២៣ មុនពេលដែលផ្នែកខ្លះបានងើបឡើងវិញមកត្រឹម ១,០២ លានដុល្លារអាមេរិកនៅក្នុងខែសីហា ឆ្នាំ២០២៣។

ហានិភ័យសំខាន់ៗសម្រាប់សេដ្ឋកិច្ចនៅក្នុងឆ្នាំ២០២៤ រួមមាន

១.តម្រូវការសកលខ្សោយជាងការរំពឹងទុក ដែលរារាំងការនាំចេញទំនិញរបស់ប្រទេសកម្ពុជា

២.លក្ខខណ្ឌហិរញ្ញវត្ថុសកលកាន់តែតឹងតែង ដែលប៉ះពាល់ដល់វិស័យហិរញ្ញវត្ថុ

៣.និងការប្រែប្រួលនៃតម្លៃប្រេង និងអាហារ ដែលបានបន្តជះឥទ្ធិពលអវិជ្ជមានដល់ការប្រើប្រាស់ក្នុងស្រុក។

ការកើនឡើងនៃបំណុលគ្រួសារ និងឥណទាននៅក្នុងវិស័យអចលនទ្រព្យនៅតែជាហានិភ័យដ៏សំខាន់ចំពោះស្ថិរភាពហិរញ្ញវត្ថុ។ លើសពីនេះ ការសម្របសម្រួលគោលនយោបាយសារពើពន្ធ-រូបិយវត្ថុនៅកម្ពុជានៅតែជាបញ្ហាប្រឈម។ ការរឹតបន្តឹងបន្ថែមទៀតនៃលក្ខខណ្ឌហិរញ្ញវត្ថុសកល ជាពិសេសការកើនឡើងអត្រាការប្រាក់សកលអាចធ្វើឱ្យការវិនិយោគនៅក្នុងវិស័យនានាកាន់តែថយចុះ និងអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធធនាគារ។

យោងទៅតាមសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១៥ ដែលធ្វើឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ប្រទេសកម្ពុជាមានគោលបំណងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលបានយកអាទិភាពកំណែទម្រង់ចំនួន ៧ ដូចខាងក្រោម៖

- បង្វែរផលប៉ះពាល់លើសេដ្ឋកិច្ចដោយសាជំងឺកូវីដ១៩ ដោយអនុវត្តអាទិភាពរយៈពេលខ្លី។
- លើកកម្ពស់ស្ថាប័នដែលមានបរិយាបន្ន និងគណនេយ្យភាពបន្ថែមទៀត ដើម្បីផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។
- ពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គម។
- វិនិយោគប្រកបដោយនិរន្តរភាពលើធនធានធម្មជាតិរបស់ប្រទេសកម្ពុជា ដើម្បីធានាបាននូវកំណើនរយៈពេលវែង។
- បន្តពង្រីក ធ្វើឱ្យប្រសើរឡើង និងធ្វើពិពិធកម្មវិស័យផលិតកម្ម ដែលមានសារៈសំខាន់សម្រាប់ភាពជោគជ័យ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា។
- ធ្វើទំនើបកម្មវិស័យកសិកម្មដោយមានការគាំទ្រពីរដ្ឋាភិបាល។
- វិនិយោគលើការអប់រំប្រកបដោយគុណភាព ការកសាងជំនាញ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។






# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ឧបត្ថម្ភក្នុងកម្មវិធី “ទិវាដើរពិភពលោក” ដើម្បីជួយលើកស្ទួយវិស័យកីឡា និងសុខភាពនៅកម្ពុជា

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តែងតែលើកស្ទួយលើវិស័យកីឡា និងសុខភាព! ធនាគារ បានចូលរួមឧបត្ថម្ភក្នុងកម្មវិធី “ទិវាដើរពិភពលោក” ដែលបានរៀបចំឡើងដោយអគ្គនាយកដ្ឋានកីឡា និងរដ្ឋបាលខេត្តព្រៃវែង សហការជាមួយ ក្រុមហ៊ុន Infinity Sport ប្រារព្ធធ្វើឡើងនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣ នៅខេត្តព្រៃវែង។

ទិវាដើរពិភពលោក ត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៩១ នៅទីក្រុងឡូសាន ប្រទេសស្វីស ដោយសមាគមពិភពលោក កីឡាសម្រាប់ទាំងអស់គ្នា ហៅកាត់ថា TAFISA។ ទិវានេះ ត្រូវបានដាក់ឈ្មោះថាជា “ទិវាដើរពិភពលោក” គឺកើតឡើងដោយមានមនុស្សរាប់លាននាក់មកពីជាង១៦០ប្រទេស បានជួបជុំដើរជុំគ្នា នៅរៀងរាល់ថ្ងៃអាទិត្យ សប្តាហ៍ទី១នៃខែតុលា។ សកម្មភាពនេះ ត្រូវបានអនុវត្តទៀងទាត់ជាង បីទសវត្ស រហូតមានការទទួលស្គាល់ពីសមាគមពិភពលោកកីឡាសម្រាប់ទាំងអស់គ្នា ហើយបានសម្រេចបង្កើតទិវានេះឡើង ដោយដាក់ឈ្មោះថា “ទិវាដើរពិភពលោក” នៅឆ្នាំ១៩៩១ ។

ដោយឡែកឆ្នាំនេះ ប្រទេសកម្ពុជា ក៏បានចូលរួម និងប្រារព្ធធ្វើឡើងលើកទី១ នៅសួនច្បារសម្តេចក្រឡាហោម ស ខេង កាលពីថ្ងៃអាទិត្យ ទី០១ ខែតុលា ឆ្នាំ២០២៣ នៅខេត្តព្រៃវែង ដោយកំណត់ម៉ោងដើរនៅវេលាម៉ោង ១០:០០ព្រឹក នៅតាមបណ្តាប្រទេសជាង ១៦០ប្រទេស។

ការចូលរួមនេះ ជាការប្តេជ្ញាតាំងចិត្តចូលរួមចំណែកលើកស្ទួយលើវិស័យកីឡា និងសុខភាព របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។










# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ឧបត្ថម្ភបង់អង្គុយជូនដល់រដ្ឋបាលក្រុងស្ទឹងត្រែង និងស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង



នាថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាខេត្តស្ទឹងត្រែង បានឧបត្ថម្ភបង់អង្គុយចំនួន ៣០ ជូនដល់រដ្ឋបាលក្រុងស្ទឹងត្រែង និង បង់អង្គុយចំនួន ២០ ជូនដល់ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង សម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋតាមទីសាធារណៈនៅក្នុងខេត្ត។











# បុគ្គលិកឆ្នើមផ្នែកប្រាក់បញ្ញើសន្សំ












ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់រង្វាន់លើកទឹកចិត្ត ស៊ីញ មាសដល់បុគ្គលិកឆ្នើម ចំពោះការសម្រេចបាននូវលទ្ធផលដ៏គាប់ប្រសើរក្នុងឆ្នាំ២០២៣។

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សម្ពោធជាផ្លូវការ សាខាស្រុកកោះធំ ដែលជាសាខាទី ៦២








ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានសម្ពោធជាផ្លូវការ សាខាទី៦២ របស់ខ្លួន គឺសាខាស្រុកកោះធំ-ឃុំព្រែកថ្មី ដែលមានទីតាំងនៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣។

ពិធីសម្ពោធជាផ្លូវការនេះ មានការចូលរួមដោយ លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ គណៈគ្រប់គ្រងជាន់ខ្ពស់នៃស្នាក់ការកណ្តាល នាយកសាខា និងបុគ្គលិកធនាគារ សាខាក្រុងតាខ្មៅ សាខាស្រុកស្អាង-ឃុំព្រែកគយ សាខាស្រុកបាទី-ឃុំត្រពាំងសាប និងសាខាស្រុកកោះធំ-ឃុំព្រែកថ្មីផ្ទាល់។

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្លាស់ប្តូរទីតាំងថ្មីរបស់ ស្នាក់ការកណ្តាល និងសាខាការិយាល័យកណ្តាល



ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានផ្លាស់ប្តូរទីតាំងថ្មីរបស់ ស្នាក់ការកណ្តាល និង សាខាការិយាល័យកណ្តាល ដែលមានទីតាំងនៅ អគារCPBankថៅវើ លេខ២៦៣ ផ្លូវលេខ១១០ កែង៦១ ក្រុម១១ ភូមិ១ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានការចូលរួមដោយ លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ គណៈគ្រប់គ្រងជាន់ខ្ពស់នៃស្នាក់ការកណ្តាល និង សាខាការិយាល័យកណ្តាលផងដែរ។

អគារថ្មីរបស់ ស្នាក់ការកណ្តាល និង សាខាការិយាល័យកណ្តាល ជាអគារស្តង់ដាធំទូលាយ ដែលត្រូវបានបំពាក់ដោយប្រព័ន្ធការពារសុវត្ថិភាព និងសម្ភារៈធនាគារទំនើបៗ។ បុគ្គលិកធនាគារ ក៏ប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌សម្រាប់បម្រើសេវាជូនអតិថិជនផងដែរ។











# កម្មវិធី ពិព័រណ៍ដែលធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចូលរួម៖






“ពិធីបុណ្យភ្ជុំបិណ្ឌ MEGA SALES” ដែលប្រព្រឹត្តឡើងចំនួន ៣ថ្ងៃ ចាប់ថ្ងៃទី៦-៨ ខែតុលា ឆ្នាំ២០២៣ នៅក្នុងផ្សារទំនើប ខេ ម៉ល វេងស្រេង (K Mall)។






ពិធីបុណ្យកាន់បិណ្ឌ (បិណ្ឌ៩) នៅវត្តឧប្បលជោត្តនារាម











ទិវាសន្សំអាស៊ាន ដែលប្រព្រឹត្តឡើងនៅថ្ងៃអង្គារ ទី៣១ ខែតុលា ឆ្នាំ២០២៣ ទីតាំងស្ថិតនៅសួនច្បារតាមដងស្ទឹងសែន ទីរួមខេត្តកំពង់ធំ











“ពិព័រណ៍ការងារ និងផលិតភាពជាតិ” ដែលប្រព្រឹត្តឡើងចំនួន ២ថ្ងៃ ចាប់ថ្ងៃទី១០-១១ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅអគារពិព័រណ៍កោះពេជ្រ

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ប្រារព្ធមហាសន្និបាតប្រចាំឆ្នាំលើកទី ១០




ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានរៀបចំមហាសន្និបាតប្រចាំឆ្នាំលើកទី១០ ដែលបានប្រារព្ធឡើងនៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ នាថ្ងៃសុក្រ ទី០៥ ខែមករា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក **តូច ចៅចេក** ប្រធាននាយកប្រតិបត្តិ និងមានការចូលរួមពីគណៈគ្រប់គ្រងជាន់ខ្ពស់ នាយក នាយិកា និងបុគ្គលិកឆ្នើមប្រចាំឆ្នាំ២០២៣ ជាច្រើនរូប។






មហាសន្និបាតនេះ ប្រារព្ធឡើងក្រោមគោលបំណងបូកសរុបលទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០២៣ និងការកំណត់ផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២៤។

មហាសន្និបាតនេះក៏បានផ្តល់ឱកាសដល់គណៈគ្រប់គ្រងទាំងអស់ក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហការគ្នាដើម្បីបង្កើនគុណភាពនៃការគ្រប់គ្រងការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសការកំណត់ផែនការយុទ្ធសាស្ត្រធ្វើយ៉ាងណាឱ្យអតិថិជនទទួលបានការផ្តល់សេវាហិរញ្ញវត្ថុល្អបំផុត។

លើសពីនេះ គណៈគ្រប់គ្រង ក៏បានប្រគល់វិញ្ញាបនបត្រសរសើរជូនសាខាឆ្នើម និងបុគ្គលិកឆ្នើមប្រចាំឆ្នាំ២០២៣ សម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបាននូវសមិទ្ធផលការងារបានយ៉ាងល្អប្រសើរ ផងដែរ។

ជាកិច្ចចុងក្រោយនៃមហាសន្និបាទ លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏បានសម្តែងនូវការកោតសរសើរដល់គណៈគ្រប់គ្រង នាយក នាយិកាសាខា និងបុគ្គលិកទាំងអស់ ចំពោះកិច្ចសហការគ្នា និងកិច្ចខិតខំប្រឹងប្រែងបានយ៉ាងល្អក្នុងការអនុវត្តន៍ការងាររយៈពេលពេញមួយឆ្នាំ។ លោកក៏បានជំរុញឱ្យគណៈគ្រប់គ្រង នាយក នាយិកាសាខា និងបុគ្គលិកទាំងអស់ ឱ្យខិតខំប្រឹងប្រែងកាន់តែខ្លាំងបន្ថែមទៀត ដើម្បីវឌ្ឍនភាពនៃធនាគារ និងខ្លួនឯង។











10th General Assembly






មហាសន្និបាតប្រចាំឆ្នាំលើកទី១០
10th General Assembly


មហាសន្និបាតប្រចាំឆ្នាំ


មហាសន្និបាតប្រចាំឆ្នាំ

MERRY Christmas & HAPPY NEW YEAR

# រីករាយបុណ្យណូអែល ពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
# Merry Christmas from CPBank!









# ហ្វូណនមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
# ផ្តល់នូវសេវាកម្មហិរញ្ញវត្ថុ លើសពីអ្វីដែលអតិថិជនត្រូវទទួល

ផលិតផលក្នុងស្រុក (ផ.ផ.ស) សម្រាប់មនុស្សម្នាក់ៗ (GDP per capita) ជាង ១.៩១៧ដុល្លារប្រចាំឆ្នាំ២០២៣ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) បានឆ្លុះបញ្ចាំងពីចំណូលប្រចាំឆ្នាំរបស់ប្រជាជនកម្ពុជា និងបញ្ជាក់ថាវិស័យមីក្រូហិរញ្ញវត្ថុនៅតែជាចលករមួយរួមចំណែកជម្រុញកំណើនសេដ្ឋកិច្ច តាមរយៈឥណទានខ្នាតតូច និងតូចបំផុតរបស់ខ្លួន។ បំពេញបន្ថែមទៅនឹងទីផ្សារគោលដៅចម្រុះ (Mass Market) របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលជាម្ចាស់ភាគទុនិក១00% នៃហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី គ្រឹះស្ថានបានផ្តោតលើសេវាកម្មហិរញ្ញវត្ថុខ្នាតតូច សម្រាប់ប្រជាជនដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាប។ ហើយនេះក៏រួមចំណែកជាមួយនឹងរាជរដ្ឋាភិបាល ដែលបានកំណត់យុទ្ធសាស្ត្រសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។






បណ្តាញការិយាល័យប្រតិបត្តិការទូទាំងប្រទេស ចំនួន៥១កន្លែង បានធ្វើឱ្យគ្រឹះស្ថានអាចទៅដល់អតិថិជនគោលដៅរបស់ខ្លួន ហើយជាមធ្យមក្នុងអតិថិជនម្នាក់មានទំហំឥណទានជាង៤.៣00ដុល្លារអាមេរិក ដែលបានផ្តល់ជូនដល់អតិថិជនសម្រាប់ប្រកបរបរកសិកម្មខ្នាតតូចជាង៣១% នៃទំហំឥណទានសរុប និងជាង១៨%ទៅលើវិស័យអាជីវកម្មផ្សេងៗ។

ក្នុងបរិបទនៃទីផ្សារមីក្រូហិរញ្ញវត្ថុ ដែលអតិថិជនគោលដៅត្រូវការ ការការពារ និងការយកចិត្តទុកដាក់បន្ថែមលើការអប់រំហិរញ្ញវត្ថុ ក្រៅពីយុទ្ធនាការអប់រំហិរញ្ញវត្ថុដល់សិស្សានុសិស្សកម្រិតថ្នាក់អនុវិទ្យាល័យ ដែលជាសកម្មភាពទំនួលខុសត្រូវសង្គមក្នុងឆ្នាំ២០២៣នេះ គ្រឹះស្ថានក៏បានសហការជាមួយសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ក្នុងកិច្ចការងារផ្សព្វផ្សាយ វីដេអូស្តីពីការអប់រំហិរញ្ញវត្ថុជាប្រចាំ ក្នុងត្រីមាសទី៤នៃឆ្នាំ២០២៣នេះផងដែរ។ តាមរយៈបណ្តាញផ្សព្វផ្សាយរបស់គ្រឹះស្ថាន វីដេអូស្តីពីការអប់រំហិរញ្ញវត្ថុ បានទៅដល់អ្នកទស្សនា (Target Audience) រាប់ម៉ឺននាក់។ លើសពីនេះ គ្រឹះស្ថានបន្តខិតខំអនុវត្តគោលការណ៍ការការពារអតិថិជនទាំងប្រាំពីរចំនុចរួមមាន៖ (១)ការបង្កើត និងការផ្គត់ផ្គង់ផលិតផលសមស្រប (២)ការបង្ការបំណុលហួសកម្រិត (៣)តម្លាភាព (៤)ការកំណត់តម្លៃសមរម្យ (៥)ភាពស្មោះត្រង់ និងការគោរពអតិថិជន (៦)ការរក្សាព័ត៌មានសម្ងាត់របស់អតិថិជន (៧)យន្តការសម្រាប់ដោះស្រាយបណ្តឹងរបស់អតិថិន។

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ខិតខំនាំមកឱ្យអតិថិជនរបស់ខ្លួនលើសេវាកម្មហិរញ្ញវត្ថុ ដែលពួកគាត់ត្រូវទទួលបាន។



# សន្និបាតប្រចាំឆ្នាំរបស់ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី



សន្និបាតបូកសរុបលទ្ធផលប្រចាំឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ត្រូវបានប្រារព្ធឡើងនៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ នាថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះបញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤។

លោកឃូ ប៊ុនទ្រី ប្រធាននាយកប្រតិបត្តិនៃគ្រឹះស្ថាន បានវាយតម្លៃខ្ពស់នូវកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងបន្តជំរុញលើកទឹកចិត្តនូវការអនុវត្តន៍សូចនាករថ្មីៗសម្រាប់ឆ្នាំ២០២៤នេះ។

ក្នុងឱកាសនេះផងដែរ គ្រឹះស្ថានបានរៀបចំសកម្មភាពក្រុម(Team Building)ដើម្បីកសាងទំនាក់ទំនងល្អរវាងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់។





